00378364

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 23 / 09 / 2009
ម៉ោង (Time/Heure): 9:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

001/18-07-2007-ECCC/TC
E1/50

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 23 / 09 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះករណី "ឌុច"
# សាធារណៈ

## សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ
## ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ -ថ្ងៃជំនុំជម្រះទី ៤៥

រៀបចំដោយ: សែ កុលវុឌ្ឍី និង Natacha WEXELS-RISER

| **កំណត់ហេតុអ្នកចូលរួម** |
| --- |
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម យូរ ឧត្តរា (បម្រុង) និង ចៅក្រម Claudia FENZ (បម្រុង) |
| ក្រឡាបញ្ជី៖ លោក Crippa MATTEO, លោកស្រី សែ កុលវុឌ្ឍី, កញ្ញា Natacha Wexels-Riser, លោក លឹម ស៊ុយហុង |
| ការិយាល័យសហព្រះរាជអាជ្ញា៖លោក William Smith, លោក សេង ប៊ុនឃាង, លោក Zachery Lampell, លោក ប៉ាក ចន្ទលីណូ, លោក Christopher Hale, លោកស្រី ជុន សុលក្ខណ៍ |

| |
|---|
| ជនជាប់ចោទ៖ លោក កាំង ហ្គេចអ៊ាវ ហៅ ឌុច |
| មេធាវីជនជាប់ចោទ៖ លោក ការ សាវុត្ថ,លោក FrançoisRoux,លោកស្រី Marie-Paule Canizares លោកស្រី Heleyn Unac, លោក ចាន់ រ៉ាវុធ,លោក Alexandre Prezanti |
| មេធាវីដំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖កញ្ញា Silke Studzinsky, លោកស្រី Martin Jacquin, លោក គឹម ម៉េងឃី, កញ្ញា ទី ស្រីនណា, លោក Alain Werner, លោក ហុង គឹមសួន |
| មេធាវីការពារសាក្សី៖ លោក គង់ សំអ៊ុន |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖លោកស្រី Maryvonne Maniacky, លោក Pierre Cozette, លោកស្រី Julie Massé, លោក សាន គីរី |

**<u>ពេលវេលាទូទៅរបស់តុលាការ៖</u>**

| | | |
|---|---|---|
| ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០០៩ | ចាប់ផ្ដើមម៉ោង៖ ៩.០០ | បញ្ចប់ម៉ោង៖ ១៦.២៥ |
| សម្រាកព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.៣៥ | បញ្ចប់ម៉ោង៖ ១០.៥០ |
| សម្រាក | ចាប់ផ្ដើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣៥ |
| សម្រាកល្ងាច | ចាប់ផ្ដើមម៉ោង៖ ១៤.៤៥ | បញ្ចប់ម៉ោង៖១៥.០០ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៥ ម៉ោង និង ២០នាទី |

**<u>កិច្ចដំណើរការនីតិវិធីផ្សេងទៀត</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| បញ្ហាទាក់ទងទៅនឹងវត្តមានរបស់មេធាវីប្រឹក្សាសម្រាប់សាក្សី និងការមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង | អង្គជំនុំជម្រះ សាក្សី ហ៊ីម ហ៊ុយ | ៩.០៥ | ៩.១០ |
| ការតាំងសំណួរទៅសាក្សី ហ៊ុម ហ៊ុយ (KW-09) | អង្គជំនុំជម្រះ | ៩.១០ | ១៦.២៤ |
| សេចក្ដីសម្រេចទៅលើសំណើសុំវិធានការការពារសម្រាប់សាក្សី KW-10 | អង្គជំនុំជម្រះ | ១៥.០៣ | ១៥.០៧ |

| | | | |
|---|---|---|---|
| ការតាំងសំណួរទៅជនជាប់ចោទ | អង្គជំនុំជម្រះ | ១៥.៤០ | ១៥.៤៦ |

| |
|---|
| **សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធី៖** |
| **បញ្ហាទាក់ទងនឹងវត្តមានរបស់មេធាវីប្រឹក្សាសម្រាប់សាក្សី និងការមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង**<br>សាក្សី ហ៊ឹម ហ៊ុយ បានចង្អុលបង្ហាញថាគាត់បានប្រឹក្សាជាមួយមេធាវីប្រឹក្សារបស់គាត់រួចហើយ និងស្នើសុំឱ្យមានវត្តមានមេធាវីប្រឹក្សារបស់គាត់នៅក្នុងអំឡុងពេលនៃការធ្វើសក្ខីកម្មរបស់គាត់។<br><br>**ការតាំងសំណួរដល់សាក្សីហ៊ឹម ហ៊ុយ**(KW-09)**ទាក់ទងនិងប្រតិបត្តិការណ៍មន្ទីរស២១ ដោយអង្គជំនុំជម្រះ**<br>• អង្គជំនុំជម្រះបានតាំងសំណួរទៅសាក្សី ហ៊ឹម ហ៊ុយ ទាក់ទងនឹងប្រតិបត្តិការណ៍មន្ទីរស២១ និង ជើងឯក។<br><br>**សេចក្តីសម្រេចលើសំណើសុំវិធានការការពារសម្រាប់សាក្សី** KW-10<br>អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចលើសំណើសុំវិធានការការពារសម្រាប់សាក្សីKW-10(សូមមើលខាងក្រោម)<br><br>**ការតាំងសំណួរទៅជនជាប់ចោទ**<br>អង្គជំនុំជម្រះបានតាំងសំណួរទៅជនជាប់ចោទទាក់ទងនឹងសក្ខីកម្មរបស់សាក្សី ហ៊ឹម ហ៊ុយ |

| **កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧.៣** | | | | |
|---|---|---|---|---|
| លេខយោងរបស់អជសដ | លេខយោងរបស់កសចស | ឈ្មោះ/ការអធិប្បាយ | ចំណាត់ថ្នាក់ឯកសារ (សំងាត់បំផុត សំងាត់ ឬសាធារណ:) | កំណត់សម្គាល់ |
| | | | | |

កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី- ១៦ កក្កដា ២០០៩ /សាធារណ:

TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E.C.C.C. C.E.T.C.

| | | | | |
|---|---|---|---|---|
| E3/404 | 4.47 | សៀវភៅ"OUKOUBAH" ដោយ Ysa OSMAN | សាធារណៈ | 00078437-00078604 ជាពិសេស 00078457 |
| E3/405 | IS 7.4 | ឈ្មោះអ្នកទោសកំទេចផ្នែក បង ហ៊ុយស្រែ | សាធារណៈ | 00242285-00242285 00006728-00006728 00250912-00250912 |
| E3/396 | D54 | កំណត់ហេតុនៃការតទល់មុខគ្នា | សម្ងាត់ | 00166561-00166570 00166588-00166599 00166571-00166580 |
| E3/406 | D19/VI | កំណត់ហេតុស្តាប់ចម្លើយសាក្សី ហ៊ឹម ហ៊ុយ | សាធារណៈ កោសលុប | 00161587-00161594 00146635-00146642 00148079-00148088 ជាពិសេស 00148082 យោងទៅពេលសវនាការដូចជាឯកសារលេខD49/6 ប៉ុន្តែដកស្រង់ពីD19/VI ដែលពីមុនបានដាក់នៅចំពោះមុខអង្គជំនុំជម្រះផ្នែកតាមវិធាន។ កោសលុបពត៌មានផ្ទាល់ខ្លួន |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- **សេចក្តីសម្រេចទៅលើសំណើសុំវិធានការការពារសម្រាប់សាក្សី KW-10**

១. នៅថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០០៩ អង្គជំនុំជម្រះបានចេញសេចក្តី សម្រេចស្តីពីវិធាន ការការពារសាក្សី និងអ្នកជំនាញ (ឯកសារ E40) ដែលនៅក្នុងសេចក្តីសម្រេចនោះមិនទាន់បានសម្រេចទៅលើសំណើសុំវិធានការការពារដែលបានស្នើឡើងដោយសាក្សីKW-10 នៅឡើយ។ នាពេលនេះអង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីនានាចំពោះសេចក្តីសម្រេចរបស់ខ្លួនលើសំណើនេះ។

២. អង្គជំនុំជម្រះបានពិនិត្យឡើងវិញទៅលើសំណើនៃការវាយតំលៃហានិភ័យ ដែលការវាយតំលៃនេះត្រូវបានចាត់ថ្នាក់ថាសំងាត់បំផុតដែលបានរៀបចំធ្វើឡើងដោយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ

(WESU) ទៅលើសាក្សី KW-10។ក្នុងការវាយតំលៃអំពីហានិភ័យ អង្គភាពគាំពារសាក្សី និងអ្នកជំនាញបានកត់សម្គាល់ថាសាក្សីរូបនេះត្រូវបានគេស្គាល់ជាសាធារណៈតាមរយៈសារព័ត៌មានជាច្រើនថាគាត់មានតួនាទីជាអ្នកសួរចម្លើយនៅមន្ទី ស-២១។ ម្យ៉ាងទៀតអង្គភាពគាំពារសាក្សី និងអ្នកជំនាញក៏បានកត់សម្គាល់បន្ថែមទៀតថាសាក្សីរូបនេះ គឺត្រូវបានគេស្គាល់ជាទូទៅដែលមិនគួរធ្វើសវនាការដោយមានវិធានការការពារនោះទេ ហើយប្រសិនបើគាត់ត្រូវធ្វើសក្ខីកម្មនៅក្នុងសវនាការជាអសាធារណៈនោះ អត្តសញ្ញាណរបស់គាត់ក៏គេដឹងដដែល។ ដោយមូលហេតុនេះ អង្គភាពគាំពារសាក្សី និងអ្នកជំនាញមិនស្នើអោយមានវិធានការការពារសម្រាប់សាក្សីនេះទេ។

៣. អង្គជំនុំជម្រះកត់សម្គាល់ឃើញថាសាក្សី KW-10 បានធ្វើអោយមានការស្គាល់អត្តសញ្ញាណរបស់គាត់ជាទូទៅ គាត់គឺជាមនុស្សដែលត្រូវបានគេស្គាល់ច្បាស់ពីតួនាទី ដែលនាំអោយវិធានការការពារមិនមានប្រសិទ្ធភាពប្រសិនបើត្រូវបានផ្តល់អោយ។ បន្ថែមលើនេះទៀត គ្រួសារ និងសាច់ញាតិរបស់គាត់ ក៏ដូចជាអ្នកជិតខាងរបស់គាត់បានដឹងពីប្រវត្តិ និងតួនាទីរបស់គាត់ដូចបានបញ្ជាក់ខាងលើស្ទើរគ្រប់ៗគ្នា។ អង្គជំនុំជម្រះសាលាដំបូងយល់ស្របទៅនឹងការស្នើឡើងដោយអង្គភាពគាំពារសាក្សី និងអ្នកជំនាញដែលថាវិធានការការពារមិនគួរផ្តល់ជូនសាក្សីរូបនេះ។

**សេចក្តីសម្រេច**

អង្គជំនុំជម្រះសាលាដំបូង **បដិសេធ** សំណើសុំវិធានការការពារសម្រាប់សាក្សី KW-10 នេះ។

សេចក្តីសម្រេចទាក់ទងនឹងវិធានការការពារសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលនៅសេសសល់នឹងចេញនៅក្នុងពេលសមស្រប។

- បង្គាប់ឲ្យនាំជនជាប់ចោទទៅមន្ទីរឃុំឃាំង និងនាំគាត់ត្រឡប់មកសវនាការវិញនៅថ្ងៃច័ន្ទ ទី២០ ខែកក្កដា ឆ្នាំ២០០៩ ។

| <u>ដីកាសម្រាប់ការលើកវារកាលសវនាការ</u> |
| --- |
| ការពន្យាពេលសវនាការ៖ សវនាការនឹងបន្តទៅថ្ងៃច័ន្ទ ទី២០ ខែកក្កដា ឆ្នាំ២០០៩ វេលាម៉ោង ៩.០០ |

001/18-07-2007-ECCC/TC
E1/50

ព្រឹក ។ SH5 NWR

ភ្នំពេញ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩

ក្រឡាបញ្ជី ក្រឡាបញ្ជី

**សែ កុលឧត្ដម** Natacha WEXELS-RISER